ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៩៤១ មស.ភព

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ ចេត្រ ឆ្នាំជូត ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០២១

**ជម្រាបមក**
**លោក លោកស្រី ប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត**

**កម្មវត្ថុ៖** ស្តីពីការប្រគល់ភារកិច្ចជូនប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ដឹកនាំ និងគ្រប់គ្រងការងារចាក់វ៉ាក់សាំងជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាក្រោមការគ្រប់គ្រងរបស់មន្ទីរនីមួយៗ។

**យោង៖**
- សេចក្តីសម្រេចលេខ៣៧សសរ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស របស់រាជរដ្ឋាភិបាល។
- សេចក្តីសម្រេចលេខ៨៧៥មស.សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតអនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ក្រសួងមុខងារជារណៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រី** ជ្រាបថា ដើម្បីធានាថាមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់នៃមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត បានទទួលវ៉ាក់សាំងកូវីដ-១៩ ក្រសួង សូមធ្វើការណែនាំ និងប្រគល់ភារកិច្ចជូនប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ដឹកនាំ និងគ្រប់គ្រងការងារចាក់វ៉ាក់សាំងកូវីដ-១៩ ដូចខាងក្រោម៖

១) អប់រំណែនាំមន្ត្រីក្រោមឱវាទពីការចាំបាច់ក្នុងការចាក់វ៉ាក់សាំងកូដវី-១៩ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងស្នើសុំឱ្យពួកគាត់ត្រៀមអត្តសញ្ញាណប័ណ្ណទៅចាក់វ៉ាក់សាំងកូវីដ-១៩

២) សហការជាមួយអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងរាជធានី ខេត្ត ដើម្បីចាក់វ៉ាក់សាំងជូនមន្ត្រីទាំងអស់របស់ខ្លួន

៣) ផ្តល់ (១)របាយការណ៍ស្តីពីវឌ្ឍនភាពនៃការចាក់វ៉ាក់សាំង និង (២)របាយការណ៍ស្តីពីអ្នកមិនទាន់បានចាក់វ៉ាក់សាំង រួចផ្ញើជូនលោក **សោម សាមេត** តាមរយៈ Telegram លេខ **០១៥២១៤៤៤៤**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី** ចាត់ចែងអនុវត្តតាមការណែនាំខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

**<u>សូមជូនភ្ជាប់មកជាមួយនូវ៖</u>**
- គំរូរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការចាក់វ៉ាក់សាំង ចំនួន០១ច្បាប់
- គំរូរបាយការណ៍ស្តីពីអ្នកមិនទាន់បានចាក់វ៉ាក់សាំង ចំនួន០១ច្បាប់។

សូម **លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**រដ្ឋមន្ត្រី**

ព្រុំ-សុខា

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ